# ខ្មែរកម្ពុជាក្រោមនិងស្តេចសីហនុ

ដោយ លី-ឌៀប ★ ថ្ងៃទី២២ មករា ២០០៧

មួយខែកន្លងមកនេះ បើនិយាយថាជា «ខែឈឺចុកចាប់» របស់ស្តេចសីហនុក៏បានដែរ ពីព្រោះនៅក្នុងអត្ថបទជាបន្តបន្ទាប់គ្នា ដែលបានចុះផ្សាយនៅក្នុងទំព័រ <វេបសាយ> គាត់សរសេរតែពីការឈឺចុកចាប់របស់គាត់ប៉ុណ្ណោះ ។ ជាថ្មីម្តងទៀត កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០០៧ ស្តេចសីហនុបានសរសេរអត្ថបទឈឺចុកចាប់មួយទៀត ដែលយើងសូមបកប្រែក្រៅផ្លូវការដូចខាងក្រោមនេះ ៖

«អនុស្សាវរីយ៍ឈឺចុកចាប់

«ខ្មែរកម្ពុជាក្រោមនិងខ្ញុំ

«ដោយ នរោត្តម-សីហនុ

«ប៉េកាំង, ថ្ងៃទី៦ មករា ឆ្នាំ២០០៧

«១- បន្ទាប់ទៅ ពួកខ្មែរត្រូវតែប្រឈមមុខនឹងការ «សងសឹក» នៃពួកជនមិនមែនខ្មែរ ដែលបានរលាស់ខ្លួនចេញពីនឹមនៃពួកខ្មែរអ្នកឈ្នះ ។

ពួកប្រឆាំងរាជានិយមបាននិយាយនិងសរសេរថា ៖ «ពួកស្តេចខ្មែរនៅក្រោយសម័យអង្គរគ្មានគុណសម្បត្តិអ្វីទេ ។ ដោយសារកំហុសរបស់ខ្លួនមួយចំនួន ពួកស្តេចអស់នោះ បានបង្កឲ្យមានការបាត់បង់កម្ពុជាក្រោម ហើយនិងខេត្តខ្មែរជាច្រើនទៅសៀម (ថៃឡង់ដ៍) ។

ភាសិតបារាំងនិយាយថា ៖ «អ្នកណាឱបខ្លាំង ចង្អៀត (ឬរួមជិតគ្នា) ក៏ខ្លាំង» ។

ស្តេចយើងហើយនិងប្រជារាស្ត្រខ្មែរដ៏ជាទីស្រឡាញ់របស់យើងបានវង្វេងភ្លើតភ្លើននឹងជ័យជំនះកងទ័ពរបស់ខ្លួន ដែលអនុញ្ញាតឲ្យរាជាធិរាជាណាចក្ររបស់ខ្លួនលាតសន្ធឹងកាន់តែឆ្ងាយទៅៗ (នឹងក្នុងទិសទីកន្លែងជាច្រើន) ពីរាជធានីអង្គរ ។

នៅផ្នែកផ្សេងទៀតនៃពិភពលោក និងនៅក្នុងជំនាន់ខុសៗគ្នា, ក៏មានស្តេច, ព្រះចៅអធិរាជ, ជនឃោរឃៅ, ជនផ្តាច់ការ (ដែលយើងដឹងជាទូទៅនោះដូចជា អាឡិចហ្សិនឌ័រ (នៃប្រទេសក្រិក), សេហ្សារ (នៃក្រុងរ៉ូម), សាល់ឡឺម៉ាញ, ប៊ូណាប៉ាតណាប៉ូឡេអុងទី១, បារាំង, អង់គ្លេស, អេស្ប៉ាញ, ព័រទុយគ្នេ, ហូឡង់, ជប៉ុន, អ៊ីត្លែរ, មូស្សូលីនី, រុស្ស៊ី និងមិនរាប់ដល់លន់-នល់និងប៉ុល-ពតនៅក្នុងនោះទេ) ។

ពួកអ្នកឈ្នះគេអស់នេះ (មិនរួមបញ្ចូលលន់-នល់ និងប៉ុល-ពត) បានចាប់ផ្តើមដោយជោគជ័យយ៉ាងត្រដែតត្រដឹម ក្នុងន័យត្រួតត្រាដែនដីនិងដែនសមុទ្រ តែ

ដល់ក្រោយមក <អ្នកដែលឱបរិតខ្លាំង ចង្អៀត (ឬរួមជិតគ្នា) ក៏ខ្លាំង> ពួកគេបកត្រឡប់ទៅជាឃើញប្រទេសដើមរបស់ខ្លួននោះ ត្រូវរួញមកតូចចង្អៀត ហើយត្រូវត្រួតត្រាដោយពួកមហាអំណាចដទៃ និងជួនកាលទៀតត្រូវកាត់ជាចំណែកដោយពួកបរទេស ។

វាជាការងាយស្រួលនិងជាអំពើអយុត្តិធម៌ ក្នុងការទម្លាក់ការទទួលខុសត្រូវនៃការបាត់បង់នៃទឹកដីអង្គររបស់យើង ទៅលើពួកស្តេចនៅក្រោយសម័យអង្គរ ។ (កកន ៖ តាមធម្មតា, ប្រវត្តិសាស្ត្របានកត់ត្រាទុកនូវអំពើល្អនិងអំពើអាក្រក់ដែលមេដឹកនាំនីមួយបានធ្វើចំពោះប្រទេសជាតិ ។ កាលធ្វើអំពើល្អ គេនាំគ្នាគោរពកោតសរសើរ ។ កាលណាធ្វើអំពើអាក្រក់ គេពុំដែលទុកឲ្យរួចខ្លួនរំភើយនោះទេ ។ គេត្រូវស្តីបន្ទោស ឬមួយត្រូវអូសកយកមេដឹកនាំនោះៗមកវិនិច្ឆ័យទោសតាមផ្លូវច្បាប់ ឧទាហរណ៍ដូចគេបានធ្វើការកាត់ទោសកាត់កស្តេចល្វីទី១៦, កាត់ទោសអ៊ីត្លែរ, ពួកមេទាហានរបស់អ៊ីត្លែរ, ការកាត់ទៅលើមូស្សូលីនី, ពួកមេទាហានរបស់មូស្សូលីនី រួចហើយនៅពេលថ្មីៗនេះ មានការកាត់ទោសព្យួរកសាដាម-ហ៊ូសេនជាដើម ។

អំពើធ្វើឲ្យបាត់បង់ទឹកដីនៅក្រោយសម័យមហានគរ ពុំអាចត្រូវដោះសាថាដោយមកពីស្តេចជាជីដូនជីតា ឬជាបុព្វការីរបស់ខ្លួន ភ្លើតភ្លើនស្រវឹងនឹងជ័យជំនះរួចហើយលោភលន់ពង្រីករាជាធិរាជាណាចក្ររបស់ខ្លួនឲ្យធំស្កឹមស្កៃនោះបានទេ ។

ស្តេចសីហនុគាត់ចង់មានន័យថា ៖ «កុំបន្ទោសអញអីយ... ពីព្រោះរឿងអីបានជាពួកអាស្តេចមុនៗនោះ វានាំគ្នាស៊ីជោរលោភលន់ចង់ពង្រីកស្រុកខ្មែរឲ្យធំធ្វើអ្វី ?? ដល់ប្រឹងក្រសោបខ្លាំងពេកទៅ វាត្រូវតែរួញរួមតូចមកចង្អៀតអញ្ចឹងឯងហើយ» ។

ស្តេចសីហនុមិនព្រមទទួលខ្លួនគាត់ ជាស្តេចសំគិសនៅក្នុងចង្កោមពួកស្តេចចោលម្សៀតនៅក្រោយសម័យអង្គរទេ... រីឯ«កំហុសនៃការបាត់បង់ទឹកដីខ្មែរ»គឺជារបស់ពួកស្តេចសម័យអង្គរទេតើ !! ។ ហេ ! ហេ !

ដល់យ៉ាងដូច្នេះទៅ... ការបាត់បង់ទឹក«កម្ពុជាក្រោម» វាមិនពុំមែនជាកំហុសស្អីរបស់គាត់នោះឯណា ។ តាមពិតទៅវាជាកំហុសរបស់ពួកស្តេចនៅមុនសម័យអង្គរឯណោះតើវិញសោះ ! ។ ម្ល៉ោះហើយសូមកុំបន្ទោសគាត់ !!...

នៅមុននេះប៉ុន្មានខែ, ស្តេចសីហនុបានសរសេរយ៉ាងដូច្នេះថា ៖ ពួកបារាំងកាត់ទឹកដីកម្ពុជាក្រោមឲ្យទៅព្រះចៅបាវដាយ ដោយសារមកពីបារាំងយល់ថា កាលណាព្រះចៅបាវដាយបានទឹកដីកម្ពុជាក្រោមមកក្នុងកណ្តាប់ដៃរបស់ខ្លួនកាលណា ប្រជាពលរដ្ឋយួននឹងនាំគ្នាស្រឡាញ់ព្រះចៅបាវដាយភ្លូកទឹកភ្លូកដី ។ប្រជាប្រិយភាពរបស់ព្រះចៅបាវដាយនឹងឡើងខ្ពស់ស្កឹមស្កៃត្រដែតត្រដឹមកប៉ពពក ពោលគឺនឹងធ្វើឲ្យបាវដាយឈ្នះសង្គ្រាមលើហូ-ជីមិញ យ៉ាងពិតប្រាកដណាស់ ។ ម៉្លោះហើយបារាំងក៏កាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួនទៅ !! វាតែប៉ុណ្ណឹងឯង !!

នេះហើយជាសំដី«ឆ្កួតជ្រូក»របស់ស្តេចសីហនុ ដែលជាស្តេចភ្លីភ្លើមួយអង្គ

នៅក្នុងចំណោមពួកស្តេចចោលម្សៀតដទៃទៀតនៅក្រោមសម័យអង្គរ ។

ពាក្យរបស់យើងពោលថា«ភ្លីភ្លើ»នេះ ប្រហែលមិនត្រឹមត្រូវចំលើអត្ថន័យនោះឡើយ ។ បើនិយាយឲ្យចំវិញ គឺគាត់ឆ្លាតទៅវិញទេ ពីព្រោះដោយសារការទុកអនុញ្ញាតឲ្យបារាំងកាត់ទឹកដីកម្ពុជាក្រោមទៅយួននេះ (ថ្ងៃទី៤ មិថុនា ឆ្នាំ១៩៤៩) គាត់បាន «ឯករាជ្យ» យកមកឲ្យស្រុកខ្មែរ និងជាពិសេសគាត់អាចស្ថិតនៅជាស្តេចសោយរាជ្យលើស្រុកខ្មែរជាបន្តទៅទៀត ។

គាត់មិននិយាយថា គាត់ចាញ់បោកបារាំង ព្រោះក្រោយពីកាត់ទឹកដីខ្មែរឲ្យទៅយួនភ្លាម បារាំងក៏ដកថយខ្លួនចេញពីឥណ្ឌូចិននោះទេ ។

ស្តេចសីហនុបានរៀបចំឆាកល្ខោនបោករាស្ត្រខ្មែរ ។ គាត់បានបង្កើត «ព្រះរាជបូជនិយកិច្ចដើម្បីទាមទារឯករាជ្យ» មានបំផុសកងទ័ពស្ម័គ្រចិត្ត និងកងនារីក្លាហានស្ពាយកាំភ្លើងឈើអត់ប្រហោង និងចំពងឫស្សី នាំគ្នាដើរហាត់(១-២)ពេញស្រុកពេញទេស ។ ឯខ្លួនគាត់បានទៅ<ភិចនិក>នៅក្នុងព្រៃអស់មួយសន្ទុះដែរ ។ គាត់ធ្វើមើលតែបារាំងហ្នឹង ភ័យស្លន់ស្លោខ្លាចកាំភ្លើងឈើនិងបំពងឫស្សីរបស់គាត់អញ្ចឹង !!

នៅក្រោយពេលបារាំងកាត់ទឹកដីកម្ពុជាក្រោមទៅយួន និងនៅក្រោមប្រទេសកម្ពុជាបានឯករាជ្យមក គេពុំដែលឃើញស្តេចសីហនុមានការតវ៉ាទាមទារអ្វីឲ្យធំដុំទេ ក្រៅអំពីបញ្ជូនគណៈប្រតិភូខ្មែររបេះរបោះទៅនិយាយជាមួយបារាំងនៅទីក្រុងបារីសម្តងពីរដងប៉ុណ្ណោះ ។ មានម្តងនោះ (បើយោងតាមសំដីសាក្សីរបស់លោកឈានវ៉ម) គាត់ថែមទាំងចេញបញ្ជាឲ្យរំលាយគណៈប្រតិភូខ្មែរ ដែលកំពុងធ្វើការតវ៉ាជាមួយបារាំង ឲ្យវិលត្រឡប់ជាប្រញាប់មកស្រុកខ្មែរវិញផង ។

នេះជា«កំហុសប្រវត្តិសាស្ត្រ»មួយដ៏ធំក្រៃលែងរបស់ស្តេចសីហនុ ដែលសាវតាខ្មែរពុំអាចកាយកប់បំភ្លេចលុបចោលបានសោះឡើយ ។

ចំនួន១០ឆ្នាំក្រោយមក ស្តេចសីហនុបានធ្វើកំហុសមួយដ៏មហាធំទៀត គឺជំនួសគាត់មិនធ្វើការតវ៉ាទាមទារយ៉ាងស្វាហាប់ គាត់មានផែនការចូលរួមដៃជាមួយហូជីមិញ ដើម្បីបង្រួបបង្រួមយួនទាំងពីរ (យួនខាងត្បូងនិងយួនខាងជើង) ឲ្យចូលគ្នាជាប្រទេសយួនតែមួយថែមទៀត ។

នៅក្រោមផែនការ«ក្បត់ជាតិខ្មែរ»នេះ ស្តេចសីហនុដែលជាស្តេចផ្តាច់ការមួយអង្គ និងក្រោយមកឡើងធ្វើជាប្រមុខអស់មួយជីវិត (លើសហ៊ុន-សែននៅក្នុងសម័យនេះដប់សួន) បានអនុញ្ញាតឲ្យពួកយៀកកុង-យៀកណាមខាងជើងតាំងមូលដ្ឋានទ័ពនៅក្នុងទឹកដីខ្មែរ តាមបណ្តោយព្រំដែនទិសខាងកើត ហើយថែមទាំងអនុញ្ញាតឲ្យចិនប្រើប្រាស់កំពង់ខ្មែរក្រុងព្រះសីហនុ សំរាប់ដឹកជញ្ជូនគ្រឿងសាស្ត្រាវុធស្បៀង និងថ្នាំពេទ្យ ឆ្លងកាត់ប្រទេសកម្ពុជាយ៉ាងគគ្រឹកគគ្រេង ផ្តល់ឲ្យពួកកងទ័ពយួនទាំងអស់នោះថែមទៀតផង ។

នៅដើមទសវត្សឆ្នាំ១៩៧០, ពេលប្រជាពលរដ្ឋខ្មែរអត់ទ្រាំនឹង«អំពើក្បត់ជាតិ»

របស់គាត់មិនបាន នាំគ្នាដង្ហែគាត់ចុះចេញពីព្រះតំណែង«ប្រមុខរដ្ឋ» គាត់ក៏ហក់ទៅធ្វើជា «ស្តេចយៀកកុង» ត្រង់ៗតែម្តង ។ គាត់បានទៅប្រមូលបនយាតករខ្មែរក្រហម មកបង្កើតជា«រណសិរ្សរួបរួមជាតិកម្ពុជា» (FUNK) និងក្រោយមកបង្កើតជា«រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» (GRUNK) ។ គាត់បានទៅបង្កើតសន្និសិទប្រជាជនឥណ្ឌូចិននៅទីក្រុងកង់តុង សាធារណរដ្ឋប្រជាមានិតចិន ដើម្បីគៀងគរកងទ័ពយៀកកុង-យៀកណាមខាងជើង ឲ្យចូលឈ្លានពានប្រទេសកម្ពុជា និងធ្វើការកាប់សម្លាប់ទៅលើប្រជាពលរដ្ឋខ្មែរ ឡើងស្ទើរពាយអស់ពីនគរ មុនពេលផ្ទេរទៅឲ្យបនយាតករខ្មែរក្រហមអនុវត្តនយោបាយ«សម្លាប់រង្គាល» យ៉ាងឃោរឃៅព្រៃផ្សៃក្រៃលែងដែលពិភពលោកនាចុងសតវត្សទី២០ ពុំដែលបានជួបប្រទះទាល់តែសោះ ។

ធ្វើកំហុសដល់ប៉ុណ្ណឹងហើយ, ស្តេចសីហនុនៅតែអះអាងថាខ្លួនគាត់អត់ខុសទៀត ។ បើតាមមើលទៅ គាត់ប្រហែលជាគិតថា កំហុសអស់ហ្នឹងជារបស់ពួកស្តេចនៅជំនាន់អង្គរទេដឹង ដែលសុទ្ធជាពួកស្តេចឆ្កួតៗ បានពង្រីកទឹកដីឲ្យធំខ្លាំងពេកទុក ពិបាកឲ្យគាត់ត្រួតត្រា ។

នៅក្រោយពេលយួនបានអនុញ្ញាតឲ្យគាត់បានឡើងសោយរាជ្យជាលើកទី២ឆ្នាំ១៩៩៣ ស្តេចសីហនុបានក្លាយជាឆ្កែលិទ្ធបាតជើងពួកអាយ៉ងយួន យ៉ាងអាក្រក់មើលក្រៃលែង ។ គាត់រហូតដល់ជំរុញឲ្យស្តេចកូន (ស្តេចសីហមុនី) ចុះហត្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែម ទទួលស្គាល់សន្ធិសញ្ញាខុសច្បាប់ដែលពួកអាយ៉ងយួនបានព្រមព្រៀងជាមួយចៅហ្វាយរបស់វា ក្នុងរយៈពេលកងទ័ពយួនឈ្លានពានប្រ-ទេសកម្ពុជា (សូមបញ្ជាក់ថា នៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិ ក៏ដូចជារបស់សន្និសិទទីក្រុងប៉ារីសឆ្នាំ១៩៩១ដែរ គេបានសរសេរពាក្យ«កងទ័ពយួនឈ្លានពានកម្ពុជា»នេះយ៉ាងច្បាស់ពិតប្រាកដណាស់) ថែមទៀត ។

ក្នុងឥឡូវនេះ ពួកយួនកំពុងតែធ្វើការបោះបង្គោលព្រំដែន យោងទៅតាមសន្ធិសញ្ញាបំពេញបន្ថែមនោះ ។ ដែលគួរឲ្យអស្ចារ្យនោះ ទ្រង់រណឫទ្ធិ ព្រះរាជបុត្រដ៏ឆ្នើមរបស់ស្តេចសីហនុ ដែលនៅកាលនោះធ្វើជា«ប្រធានរដ្ឋសភាកញ្ចប់» ជារដ្ឋសភាផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាបំពេញបន្ថែម ក្រោយមកនិយាយថា ខ្លួនមិនទាំងដឹងថា ព្រំសីមាខ្មែរនៅត្រង់កន្លែងណាផង ពោលគឺគាត់ធ្វើទាំងងងឹតងងុល មិនខ្វល់អំពល់អ្វីទាំងអស់ ឲ្យតែរក្សាផលប្រយោជន៍របស់ខ្លួន (រួមទាំងតំណាងរាស្ត្រទាំងអស់នៃគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចផង ដែលជាអ្នកបោះឆ្នោតគាំទ្រ) ។

សួរថា តើសន្ធិសញ្ញាបំពេញបន្ថែមមានន័យយ៉ាងណាចំពោះខ្មែរកម្ពុជាក្រោម? រឿងនេះស្តេចសីហនុគាត់ធ្វើពើជាមិនដឹង ឬមួយគាត់ចាត់ទុកថាជាកំហុសរបស់ស្តេចសម័យអង្គរដែលពង្រីកទឹកដីធំពេក ។ ការបោះបង្គោលព្រំដែន គឺជាការបែងចែកប្រទេសកម្ពុជា «ជាផ្លូវការ» ចេញពីទឹកដី«កម្ពុជាក្រោម» ដែលឥឡូវនេះយួនបានចាត់ទុកជាទឹកដីរបស់ផែនវាទៅហើយ ។

ដល់ដូច្នេះទៅ... យើងមើលពុំឃើញសោះ អំពីស្តេចសីហនុខិតខំទាមទារទឹកដីកម្ពុជាក្រោមពីយួន) ។ រឿងដែលគួរឲ្យចង់សើចនោះ គឺស្តេចសីហនុគាត់មិនបញ្ចូលលោកលន់-នល់ ទៅក្នុងចំណោមពួកមេដឹកនាំដែលចង់ធ្វើឲ្យប្រទេសរីកធាត់ធំទេ (ប៉ុល-ពតជាកូនចៅរបស់ស្តេចសីហនុ ។ អាចជាមនុស្សដែលសីហនុចាក់ឲ្យវាយយួន ដើម្បីយួនមានលេសចូលឈ្លានពានស្រុកខ្មែរ) ។ លោកលន់-នល់ជាអ្នកបណ្តេញយួនឲ្យចេញពីទឹកដីខ្មែរ ប្រឆាំងនឹងគំនិតរបស់ស្តេចសីហនុ ដើម្បីថែរក្សាឯករាជភាព និងបូរណភាពទឹកដីខ្មែរសោះ បែរជាត្រូវស្តេចសីហនុដែលជាអ្នកទៅគៀងយួនឲ្យចូលឈ្លានពានស្រុកខ្មែរ ចោទប្រកាន់ជាអ្នក«ខុស»ទៅវិញ ។ គិតទៅម៉្យាងដែរតើ !!

«ធ្វើជាស្តេច គ្មានស្តេចណាមួយដែលពុំចង់បានព្រះរាជាណាចក្ររបស់ខ្លួនធំធាត់ តាមដែលអាចធ្វើទៅបាននោះឡើយ ។

(<u>កកន</u> ៖ ឃ្លារបស់ស្តេចសីហនុត្រង់នេះ ហាក់ដូចជាកំពុងជាន់កែងខ្លួនឯង) ។

«ប្រជាពលរដ្ឋវៀតណាម (អាណ្ណាម) និងថៃ ក្នុងការប្រៀបធៀបជាមួយប្រជាពលរដ្ឋខ្មែរ ជាពិសេសប្រជាពលរដ្ឋ«ក្មេងៗ» ដែលនៅក្នុងចំណុចមួយ មានការត្រេកត្រអាលនិងមានកម្លាំង ដើម្បីវាយប្រហារខ្មែរ ហើយនិងដាក់វេនគ្នាដើម្បីត្រួតត្រាដែនដីនិងដែនសមុទ្រ ។ ជា «តថភាព», រឿងនេះគឺសំរាប់គ្រាន់តែដើម្បីបំផ្លាញកម្ពុជាប៉ុណ្ណោះ ។

(<u>កកន</u> ៖ ពួកក្មេងយួន-សៀមវាមុខជាចង់បានស្រុកខ្មែរអញ្ចឹងហើយ ពីព្រោះស្រុកខ្មែរមានផលប្រយោជន៍ដល់ស្រុកនិងជនជាតិរបស់វាដ៏មានចំនួនយ៉ាងច្រើននោះ ចុះហេតុអ្វីបានជា«ស្តេចកញ្ចាស់ខ្មែរ»បែរទៅជាបេះស្រុកខ្មែរចែកឲ្យគេទៅវិញ រួចហើយស្រែកជេរស្តេចសម័យអង្គរ ថាជាអ្នកមានកំហុសខំពង្រីកទឹកដីឲ្យធំហួសមាឌយ៉ាងដូច្នេះ ??) ។

«ពាក់ព័ន្ធនឹងកម្ពុជាក្រោមវិញ, ពួកបារាំងដែលជាអ្នកកសាងអាណាចក្រនៅក្រោម ណាប៉ូឡេអុងទី១ នោះ រួចក្រោយមកក្លាយជាជនធ្វើអាណានិគមយ៉ាងពិតប្រាកដនៅក្រោម ណាប៉ូឡេអុងទី៣ រួចហើយផងដែរ «សាធារណរដ្ឋបារាំងទី៣» បានលូកដៃក្នុងកម្ពុជាក្រោមប្រហែលឆ្នាំ១៨៦០ ធ្វើការសំរុះសំរួលខ្មែរនិងអាណ្ណាមដែលកំពុងច្បាំងគ្នាពេលនោះ ប្រកាសជា «កូសាំងស៊ីន» ធ្វើជា «អាណានិគមបារាំង» ធ្វើការបញ្ចៀសដោយប្រើកម្លាំង មិនឲ្យកម្ពុជាយកត្រឡប់មកវិញនូវកម្ពុជាក្រោមរបស់ខ្លួន (ដែលបារាំងហៅថា កូសាំងស៊ីន ដើម្បីជៀសវាងមានការទទួលស្គាល់ជារបស់ផិនខ្លួននៃកម្ពុជា) ហើយនិងករិតមហិច្ឆិតារបស់អាណ្ណាម...

( នៅមានត )

«ព្រះហត្ថលេខា ៖ នរោត្តម-សីហនុ» ។

(<u>កកន</u> ៖ បារាំងធ្វើនេះជាផលប្រយោជន៍ឲ្យយួន ។ ស្តេចសីហនុនិងពួកមេៗខ្មែរនៅ

សម័យនោះពុំមែនមិនដឹងឯណា គឺសុទ្ធតែបានដឹងទាំងអស់ ។ ចំណុចដែលយើងជាខ្មែរជំនាន់ក្រោយស្តេចសីហនុចង់ដឹងនោះគឺថា ចុះហេតុអ្វីបានជានៅពេលប្រទេសកម្ពុជាបានទទួលឯករាជភាពពេញបរិបូណ៌ហើយ (ក្រោយថ្ងៃទី៩ វិច្ឆិកា ១៩៥៣) ស្តេចសីហនុពុំដែលធ្វើការតវ៉ាទាមទារទឹកដីកម្ពុជាក្រោមមកវិញសោះយ៉ាងដូច្នេះ ? ចុះហេតុអ្វីបានជា១០ឆ្នាំក្រោយមកទៀត ស្តេចសីហនុមានផែនការបង្រួបបង្រួមយួនទាំងពីរឲ្យចូលគ្នា ? ។ ហើយចុងក្រោយ ចុះហេតុអ្វីបានជាស្តេចសីហនុជំរុញឲ្យកូនចុះហត្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាឆ្នាំ១៩៨៥ ?? ។ តើទាំងនេះពុំមែនមានន័យថា ស្តេចសីហនុក្បត់ជាតិ ចូលដៃជាមួយយួនប្រឆាំងជាមួយពួកស្តេចនៅសម័យមហានគរទេឬ ??) ។

❀ ❀

❀